# ធម្មកថិក

(អ្នកសម្ដែងធម៌)



**ដោយ ខេមរ អភិធម្មាវតារ**

**ព.ស. ២៥៦១**

# ធម្មកថិក

**ធម្មកថិក** ( ន. ) [ *ធ័ម-ម:ក: ថិក]* ( *បា., សំ.* ) (ធមិកថិក) អ្នកសំដែងធម៌ ។

ខ្មែរប្រើពាក្យនេះជាងារនៃភិក្ខុអ្នកចេះសំដែងធម៌ ថ្នាក់ជាឋានានុក្រម ជាសហការីនៃព្រះរាជាគណៈជាចៅអធិការវត្តធំៗ ក្នុងព្រះរាជធានី ឬជាសហការីនៃមេគណ កាលបើត្រូវការឲ្យមាន : *ព្រះធម្មកថិក សហការីនៃ...(ម. ព. ធម្មធរ និង វិន័យធរ ទៀតផង) ។*

*(វចនានុក្រមសម្ដេចជួន ណាត)*

**ធម្មកថិក** (បុំ.) [ធម្ម + កថ + ឥក] វិគ្គហៈថា ធម្មំ កថេតីតិ > ធម្មកថិកោ អ្នកណាពោលនូវធម៌ ព្រោះហេតុនោះ អ្នកនោះ ឈ្មោះថា ធម្មកថិក (អ្នកសំដែងនូវធម៌)។

(សទ្ទានុក្រមបាលី)

## ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មឈ្មោះថាព្រះធម្មកថិក

*អាភិធម្មិកភិក្ខុយេវ កិរ ធម្មកថិកា នាម បានឮថាភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មប៉ុណ្ណោះ ឈ្មោះថា ព្រះធម្មកថិក ក្រៅពីនេះ សូម្បីពោលធម៌ ក៏មិនមែនធម្មកថិក ។ ព្រោះហេតុអ្វី ? ព្រោះថា ភិក្ខុអ្នកមិនទ្រទ្រង់ព្រះអភិធម្មទាំងនោះ កាលពោលធម៌ តែង ពោលតាមលំដាប់កម្ម លំដាប់វិបាក ការកំណត់រូបនិងអរូប ធ្វើលំដាប់ធម៌ឲ្យច្រឡូកច្រឡំ ។ ចំណែកភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្ម មិនឲ្យលំដាប់ធម៌ច្រឡូកច្រឡំ ។ ព្រោះដូច្នោះ ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មនឹងពោលធម៌ ឬ មិនបានពោលក៏ដោយ តែក្នុងកាលដែលគេសួរបញ្ហា ហើយក៏នឹងពោលដោះស្រាយបញ្ហានោះបាន ព្រះសាស្ដាទ្រង់សំដៅដល់ពាក្យនេះថា : **ភិក្ខុទ្រទ្រង់ព្រះអភិធម្មប៉ុណ្ណោះ ឈ្មោះថា ធម្មកថិក**ដោយចំណែកមួយ ដូច្នេះ ទើបទ្រង់ប្រទានសាធុការហើយ ត្រាស់ថា **មោគ្គល្លានពោលល្អហើយ** ។*

*(អដ្ឋសាលិនី អដ្ឋកថា អភិធម្មបិដក ធម្មសង្គណិ និទានកថា)*

## ភិក្ខុបានឈ្មោះថា ធម្មកថិក ត្រូវប្រកបដោយអង្គ ៥ យ៉ាង

១. ម្នាលភិក្ខុ បើភិក្ខុសម្តែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរំលត់រូប ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។

២. ម្នាលភិក្ខុ បើភិក្ខុសម្តែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរំលត់វេទនា ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។

៣. ម្នាលភិក្ខុ បើភិក្ខុសម្តែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរំលត់សញ្ញា ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។

៤. ម្នាលភិក្ខុ បើភិក្ខុសម្តែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បី សេចក្តីរំលត់សង្ខារ ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។

៥. ម្នាលភិក្ខុ បើភិក្ខុសម្តែងធម៌ ដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បី សេចក្តីរំលត់វិញ្ញាណ ទើបគួរហៅថា ភិក្ខុជាធម្មកថិក ។

( សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវគ្គ ខន្ធសំយុត្ត ធម្មកថិកវគ្គ ធម្មកថិកសូត្រ បិដកលេខ ៣៤ ទំព័រ ១៤ និង ទុតិយធម្មកថិកសូត្រ បិដកលេខ ៣៤ ទំព័រ ១៦)

## ភិក្ខុបានឈ្មោះថា ធម្មកថិក ត្រូវប្រកបដោយអង្គ ៦ យ៉ាង

១. បើភិក្ខុសម្តែងធម៌ ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវចក្ខុ ទើបគួរ ហៅថាភិក្ខុជាធម្មកថិក ។

២. បើភិក្ខុសម្តែងធម៌ ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវសោតៈ ទើបគួរ ហៅថា ភិក្ខុជាធម្មកថិក ។

៣. បើភិក្ខុសម្តែងធម៌ ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវឃាន: ទើបគួរ ហៅថាភិក្ខុជាធម្មកឋិក ។

៤. បើភិក្ខុសម្តែងធម៌ ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវជិវ្ហា ទើបគួរ ហៅថាភិក្ខុជាធម្មកឋិក ។

៥. បើភិក្ខុសម្តែងធម៌ ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវកាយ ទើបគួរ ហៅថាភិក្ខុជាធម្មកឋិក ។

៥. បើភិក្ខុសម្តែងធម៌ ដើម្បីនឿយណាយ ដើម្បីវិនាស ដើម្បីរំលត់ នូវចិត្ត ទើបគួរ ហៅថាភិក្ខុជាធម្មកឋិក ។

(សុត្តន្តបិដក សំយុត្តនិកាយ សឡាយតនវគ្គ តតិយបណ្ណាសក: នវបុរាណវគ្គ ធម្មកឋិកបុច្ឆសូត្រ បិដកលេខ ៣៥ ទំព័រ ៣២៤)

## ភិក្ខុបានឈ្មោះថា ធម្មកឋិក ត្រូវប្រកបដោយអង្គ ១២ យ៉ាង

១. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់ នៃជរាមរណ: ទើបគួរហៅថា ភិក្ខុជាធម្មកឋិកបាន ។

២. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃជាតិ ទើបគួរហៅថា ភិក្ខុជាធម្មកឋិកបាន ។

៣. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃភព ទើបគួរហៅថា ភិក្ខុជាធម្មកឋិកបាន ។

៤. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃឧបាទាន ទើបគួរហៅថា ភិក្ខុជាធម្មកឋិកបាន ។

៥. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃតណ្ហា ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

៦. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃវេទនា ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

៧. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃផស្សៈ ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

៨. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃសឡាយតនៈ ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

៩. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃនាមរូប ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

១០. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃវិញ្ញាណ ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

១១. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃសង្ខារ ទើបគួរហៅថា ភិក្ខុជាធម្មកថិកបាន ។

១២. បើភិក្ខុសំដែងធម៌ ដើម្បីការនឿយណាយ ដើម្បីការវិនាស ដើម្បីការរលត់នៃអវិជ្ជា ទើបគួរហៅថា ភិក្ខុធម្មកថិក ។

( សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ និទានសំយុត្ត អាហារវគ្គ ធម្មកថិកសូត្រ បិដកលេខ ៣១ ទំព័រ ៣៧)

ដោយខេមរ អភិធម្មាវតារ